**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

ការិយាល័យ : ផ្ទះលេខ ៩-១១, ផ្លូវ ៤៧៦ ទួលទំពូង ១
ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ-៣
ទូរស័ព្ទលេខ: ០២៣ ២១៤ ៤២៩
ទូរសារលេខ: ០២៣ ៩៩៤ ០៦៣
អ៊ីម៉ែល : ngoforum@ngoforum.org.kh
គេហទំព័រ : www.ngoforum.org.kh

ព្រឹត្តិប័ត្រប្រចាំឆមាស

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
*The NGO Forum on Cambodia*

# ដីជីវិត

ឆ្នាំទី ៦ ~ លេខ ១៣

ខែមករា ~ ខែមិថុនា ឆ្នាំ ២០១០

**បណ្តាញសកម្មភាពដីធ្លីដើម្បីអភិវឌ្ឍន៍**

- ភាពមិនជោគជ័យក្នុងការដោះស្រាយវិវាទដីធ្លី
- សហគមន៍ "កំពុងតែមានការព្រួយបារម្ភ..."
- ស្ថានភាពជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា...
- សហគមន៍ព្រៃឈើ នៅឃុំអូគ្រៀង
- ការបង្កើតសហគមន៍ និងការដោះស្រាយវិវាទដីធ្លី









**កម្មវិធីដីធ្លី និងជីវភាព**

១- គម្រោងបញ្ហាដីធ្លី

២- គម្រោងតាំងទីលំនៅថ្មី និងសិទ្ធិលំនៅដ្ឋាន

៣- គម្រោងសិទ្ធិជនជាតិដើមភាគតិច

៤- គម្រោងជីវភាពអាស្រ័យព្រៃឈើ និងចំការឈើដាំ

ព្រឹត្តិប័ត្រប្រចាំឆមាស

ឆ្នាំទី ៦ ~ លេខ ១៣

ខែមករា ~ ខែមិថុនា ឆ្នាំ ២០១០

# ដីជីវិត

## បណ្តាញសកម្មភាពដីធ្លីដើម្បីអភិវឌ្ឍន៍

### អារម្ភកថា

មិត្តអ្នកអានជាទីមេត្រី ព្រឹត្តិប័ត្រដែលកំពុងស្ថិតក្នុងដៃរបស់អស់លោកអ្នកនេះ គឺកើតចេញពីការខិតខំប្រឹងប្រែងរបស់បុគ្គលិកនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដោយមានការចូលរួមចំណែកពីសមាជិកបណ្តាញសកម្មភាពដីធ្លីដើម្បីអភិវឌ្ឍន៍ បណ្តាញប្រព្រឹត្តិកម្មតាំងទីលំនៅថ្មី បណ្តាញគាំទ្រសិទ្ធិជនជាតិដើមភាគតិច និង បណ្តាញការងារព្រៃឈើ និងចំការឈើដាំ។ ក្នុងនាមវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដែលមានជំហរលើការចែករំលែកព័ត៌មាន ជជែកពិភាក្សាលើការផ្លាស់ប្តូរគោលនយោបាយ និងសកម្មភាពអភិវឌ្ឍន៍នៅកម្ពុជា យើងសូមគាំទ្រដល់ការបោះពុម្ពព្រឹត្តិប័ត្រនេះ ដើម្បីចូលរួមចំណែកផ្តល់នូវចំណេះដឹងនានាដែលពាក់ពន្ធ័នឹងការអនុវត្តច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា និងដើម្បីអោយមិត្តអ្នកអានបានដឹងថានរណាខ្លះដែលកំពុងនឹងបានក្លាយខ្លួនទៅជាក្រុមជនងាយរងគ្រោះ ដោយសារការបាត់បង់ដីធ្លីនៅកម្ពុជា។

លើសពីនេះទៀត ព្រឹត្តិប័ត្រនេះក៏បានលើកឡើងនូវសំលេង និងផលវិបាកទាំងអស់របស់ប្រជាពលរដ្ឋក្រីក្រទាក់ទងទៅនឹងបញ្ហាដីធ្លីដើម្បីអោយអ្នកធ្វើគោលនយោបាយទាំងអស់បានដឹងឮ និងងាកមកយកចិត្តទុកដាក់នូវអ្វីដែលជាអាទិភាពសំរាប់ឆ្លើយតបទៅនឹងតំរូវការរបស់ប្រជាពលរដ្ឋ។

យើងខ្ញុំសូមស្វាគមន៍យកនូវមតិយោបល់កែលំអ និងស្ថាបនាឱ្យមានភាពប្រសើរឡើងទាំងផ្នែកព័ត៌មាន និងចំណេះដឹង យើងខ្ញុំនឹងព្យាយាមបំពេញតាមតំរូវការរបស់អស់លោកអ្នក។

ព្រឹត្តិប័ត្រប្រចាំឆមាស

គណៈកម្មការនិពន្ធ និងត្រួតពិនិត្យ

លោក ឈិត សំអាត — នាយកប្រតិបត្តិ

លោក ខាំ ស៊ីខួន — នាយកប្រតិបត្តិរង

លោក ប៉ែន រង្សី — ប្រធានកម្មវិធីដីធ្លី និង ជីវភាព

លោកស្រី នូច សេដ្ឋា — មន្ត្រីគម្រោងដីធ្លី

រចនាអត្ថបទដោយ

លោក ត្នួន យូ — មន្ត្រីព័ត៌មាន និងការបោះពុម្ពផ្សាយ



# ភាពមិនជោគជ័យក្នុងការដោះស្រាយវិវាទដីធ្លី

វិវាទដីធ្លី គឺជាបញ្ហាមួយដ៏ក្តៅគគុកដែលកំពុងកើតមានឡើងជាច្រើនករណីនៅក្នុងប្រទេសកម្ពុជា ព្រមទាំងបានផ្សព្វផ្សាយនៅលើទំព័រសារព័ត៌មាន វិទ្យុ និងទូរទស្សន៍ស្ទើរជារៀងរាល់ថ្ងៃ។ យោងទៅតាមច្បាប់ និងអនុសាសន៍របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងថា បញ្ហាវិវាទដីធ្លីពុំអនុញ្ញាតឱ្យមានការចាប់ឃុំខ្លួនអ្នកធ្វើការតវ៉ាទាមទារយកដីរបស់ខ្លួនដាក់ក្នុងពន្ធនាគារឡើយ[1] ប៉ុន្តែបើពិនិត្យទៅលើការអនុវត្តជាក់ស្តែងវិញ គឺមានតំណាងប្រជាពលរដ្ឋជាច្រើននាក់ដែលធ្វើការតវ៉ាទាមទារយកដីរបស់ខ្លួនត្រូវបានតុលាការចាប់ឃុំខ្លួននៅក្នុងពន្ធនាគារ។ ជាមួយគ្នានេះ អាជ្ញាធរមានសមត្ថកិច្ចបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ដោះស្រាយទាំងតាមផ្លូវតុលាការ និងតាមការសម្រុះសម្រួលក្រៅប្រព័ន្ធតុលាការ។ ក្នុងនោះមានសំណុំរឿងជាច្រើនត្រូវបានដោះស្រាយសម្រុះសម្រួលគ្នានឹងបញ្ចប់ទៅដោយសន្តិវិធី ហើយមួយចំនួនទៀត ក៏កំពុងតែធ្វើការដោះស្រាយ។ ប៉ុន្តែមានការកត់សំគាល់ឃើញថា មានសំណុំរឿងវិវាទដីធ្លីជាច្រើនករណីទៀត មិនមានការយកចិត្តទុកដាក់ក្នុងការដោះស្រាយ ដោយទុកឱ្យកកស្ទះ ហើយភាគីអ្នកមានលុយឬមានអំណាចនៅតែមានសកម្មភាពបន្តលើដីវិវាទនោះ។

*តើវិវាទដីធ្លីចំការកៅស៊ូរមាសហែក ស្ថិតនៅឃុំត្រស់ ស្រុករមាសហែក ខេត្តស្វាយរៀងមានដំណើរការដោះស្រាយយ៉ាងដូចម្តេច? តើកត្តាអ្វីខ្លះជាមូលហេតុធ្វើឱ្យការដោះស្រាយមិនទទួលបានជោគជ័យ?*

វិវាទដីធ្លីរវាងប្រជាពលរដ្ឋចំនួន ៣ភូមិ ក្នុងឃុំត្រស់ និងក្រុមហ៊ុនចំការកៅស៊ូរមាសហែក ដែលជាសាខារបស់ចំការកៅស៊ូជប់ពាមជាំង បានចាប់ផ្តើមកើតមានឡើងតាំងពីឆ្នាំ២០០៧មកម្ល៉េះ ហើយបច្ចុប្បន្នក៏ពុំទាន់មានការដោះស្រាយចប់នៅឡើយដែរ។ បើនិយាយពីប្រវត្តិដីទំនាស់នេះ ក្រុមអ្នកភូមិបានអះអាងថា កាលពីដើមតំបន់នេះជាតំបន់ព្រៃ ពួកគាត់បានចូលទៅកាប់ឆ្ការកាន់កាប់ចាប់ពីអំឡុងឆ្នាំ១៩៨០ ដើម្បីធ្វើស្រែចំការ ដោយពុំមានបុគ្គល ឬអាជ្ញាធរណាមួយមករារាំង ឬហាមឃាត់ពួកគាត់ឡើយ ទើបតែមកដល់ឆ្នាំ ២០០៣ ក្រុមមន្ត្រីរដ្ឋបាលព្រៃឈើបានហាមឃាត់ប្រជាពលរដ្ឋមិនឱ្យកាប់រានដីព្រៃបន្តទៀត។ បន្ទាប់មកក្នុងឆ្នាំ ២០០៦ អាជ្ញាធរខេត្តបានដកហូតដីរបស់ពួកគាត់ និង ដីព្រៃនៅតំបន់នេះ រក្សាទុកជាដីព្រៃរបស់រដ្ឋ។ នៅឆ្នាំ ២០០៧ ក្រុមហ៊ុនចំការកៅស៊ូរមាសហែក បានឈូសឆាយដោយមិនមានការដោះស្រាយសំណងទេ។ បច្ចុប្បន្នចំការកៅស៊ូនេះ បានផ្ទេរទៅអោយក្រុមហ៊ុន **អាន ម៉ារឌី គ្រុប** គ្រប់គ្រងបន្ត ហើយបានជីកប្រឡាយ ធ្វើព្រំហ៊ុមព័ទ្ធដីរបស់ប្រជាពលរដ្ឋនៅដើមឆ្នាំ ២០១០ ពេលនោះអ្នកភូមិ ក៏បានធ្វើការតវ៉ាឱ្យក្រុមហ៊ុនបញ្ឈប់សកម្មភាពឈូសឆាយដីនេះដែរ។

យោងតាមព័ត៌មានដែលក្រុមការងារបណ្តាញដីធ្លីប្រចាំខេត្តស្វាយរៀងទទួលបានពី លោក **ចាន់ សាវ៉ាន់** អគ្គលេខាធិការសាលាខេត្តស្វាយរៀង បង្ហាញថា គណៈកម្មការដោះស្រាយវិវាទដីធ្លីខេត្តស្វាយរៀង បានចុះសិក្សាស្រាវជ្រាវពីចំនួនសមាជិកគ្រួសារនីមួយៗ និងទំហំដីរបស់ប្រជាពលរដ្ឋ ដែលស្ថិតក្នុងប្លង់ក្រុមហ៊ុន។ ជាក់ស្តែងនៅក្នុង ជំហានទី១: រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ១៦៦. អនក្រ.បក ចុះថ្ងៃទី០៩ តុលា ឆ្នាំ២០០៩ ស្តីពីការផ្ទេរដី ទំហំ៣៥០ហិកតា ជាដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន **អាន ម៉ារឌី គ្រុប** ស្ថិតនៅឃុំត្រស់ និង ឃុំគគីស្រុករមាសហែក ខេត្តស្វាយរៀង សម្រាប់ធ្វើសម្បទានសង្គមកិច្ច[2]។ ជំហានទី២: បានចេញអនុក្រឹត្យលេខ ១៦៧. អនក្រ.បក ចុះថ្ងៃទី០៩ តុលា ឆ្នាំ ២០០៩ ស្តីពី ការធ្វើអនុប្បយោគដីព្រៃបំរុងទុករបស់រដ្ឋ ទំហំ ៤៧.៤៧៤ ហិកតា ឃុំត្រស់ និង ឃុំគគី ស្រុករមាសហែក ខេត្តស្វាយរៀង សម្រាប់ធ្វើសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋ

[1] សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន មានប្រសាសន៍នៅថ្ងៃទី១៥ ខែមិនា ឆ្នាំ២០០៦ ពេលធ្វើសវនាការជាមួយ NGOs នៅភូមិគ្រឹះរបស់សម្តេច និងនៅពេលដែលសម្តេចបានចុះដោះស្រាយទំនាស់ដីធ្លីនៅខេត្តព្រះសីហនុ ក្នុងឆ្នាំ២០០៧។

[2] អនុក្រិត្យស្តីពីការផ្ទេរដីទំហំ៣៥០ហិកតាចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អាន ម៉ាឌី គ្រុប ស្ថិតនៅឃុំត្រស់ ស្រុករមាសហែក ខេត្តស្វាយរៀង និងអនុក្រិត្យ ស្តីពីការធ្វើអនុបយោគ ដីព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋសំរាប់សម្បទានដីសង្គមកិច្ច ស្ថិតនៅឃុំត្រស់ ស្រុករមាសហែក ខេត្តស្វាយរៀង។

ទាំងបីភូមិ។ ជាមួយគ្នានេះ អាជ្ញាធរខេត្តស្វាយរៀង មានបញ្ជីឈ្មោះប្រជាពលរដ្ឋ ចំនួន៥ភូមិ ប្រជាពលរដ្ឋ សរុប ៧៣៥គ្រួសារ (ភូមិត្រស់ ១៨៦គ្រួសារ ភូមិបឹង ១៨០គ្រួសារ ភូមិតាសួស ១៣៤ គ្រួសារ ភូមិម្រាក់ទាប ១៣០គ្រួសារ និង ភូមិទំពាំងបន្ទាយ ១០៥គ្រួសារ) ស្មើនឹងផ្ទៃដី ៨២.៤៧៤ ហិកតា ដែលត្រូវទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋ ក្នុង១គ្រួសារ ទំហំចន្លោះពី ១០ អារ ទៅ ១,៥០ ហិកតា ។



ដីប្រជាពលរដ្ឋក្នុងទីតាំងទំនាស់



ដីប្រជាពលរដ្ឋក្នុងទីតាំងទំនាស់



ប្រឡាយព្រំប្រទល់ដីរបស់ក្រុមហ៊ុន

ប៉ុន្តែបើយោងតាមរបាយការណ៍មួយទៀត ដែលលោកអភិបាលរងខេត្ត និងមន្ត្រីពាក់ព័ន្ធ បានយកទៅប្រកាសផ្តល់ដីសម្បទានសង្គមកិច្ចដល់ប្រជាពលរដ្ឋភូមិត្រស់ នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០ នៅបរិវេណវត្តត្រស់ គឺមានការផ្ទុយពីរបាយការណ៍ ដែលអគ្គលេខាធិការសាលាខេត្តបង្ហាញដល់ក្រុមការងារបណ្តាញដីធ្លី។ ជាឧទាហរណ៍: ស្ថិតិប្រជាពលរដ្ឋ នៅភូមិត្រស់ ពិតប្រាកដមាន ១៣០គ្រួសារ តែនៅក្នុងឯកសារស្នើសុំដីសម្បទានបានតំឡើងដល់ ១៨៦គ្រួសារ តែនៅពេលប្រកាសបែងចែក ជាក់ស្តែងមានតែប្រជាពលរដ្ឋចំនួន ៨១គ្រួសារ ប៉ុណ្ណោះ ដែលមានឈ្មោះទទួលបានដី ក្នុងនោះមាន ១៧ គ្រួសារដែលមិនមែនជាឈ្មោះប្រជាពលរដ្ឋរស់នៅក្នុងភូមិត្រស់ទេ ហេតុដូច្នេះហើយប្រជាពលរដ្ឋភូមិត្រស់ ដែលទទួលបានដីពិតប្រាកដមានចំនួនតែ ៦៤ គ្រួសា និង៦៦គ្រួសារទៀតមិនបានទទួលដីសម្បទាននោះទេ ទើបប្រជាពលរដ្ឋទាំងអស់ មិនព្រមទទួលយក និង នាំគ្នាដើរចេញពីអង្គប្រជុំ។

ជាទីបញ្ចប់ ក្រុមការងារបណ្តាញដីធ្លី បានកត់សំគាល់ឃើញនូវកត្តាគន្លឹះមួយចំនួន ដែលនាំឱ្យការដោះស្រាយទំនាស់ដីធ្លីនេះមិនទទួលបានជោគជ័យ ដូចខាងក្រោម:

- ការប្រកាសផ្តល់ដីសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋទទួលរងផលប៉ះពាល់មិនបានគ្រប់គ្រួសារដោយយករបាយការណ៍ ដែលមានទិន្នន័យផ្ទុយពីរបាយការណ៍របស់អគ្គលេខាធិការសាលាខេត្តស្វាយរៀងដែលបានបង្ហាញសមាជិកបណ្តាញដីធ្លី។
- កង្វះទំនាក់ទំនង និងការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋប្រកបដោយតម្លាភាព។
- ទីតាំងដីសម្បទានសង្គមកិច្ចដែលរដ្ឋផ្តល់ឱ្យនៅឆ្ងាយពីភូមិ ប៉ុន្តែប្រជាពលរដ្ឋចង់បាននៅជាប់ភូមិរបស់គាត់។
- ជាគោលការណ៍ដែលបានចែងនៅក្នុងអនុក្រឹត្យនៃការផ្តល់ដីសម្បទានរដ្ឋ នឹងផ្តល់ដីឱ្យប្រជាពលរដ្ឋ ទំហំចន្លោះ ពី ១០ អារ ទៅ ១,៥០ ហិកតា ក្នុង១គ្រួសារ ទោះបីប្រជាពលរដ្ឋមានដីទំហំប៉ុណ្ណាក៏ដោយ។

## អនុសាសន៍

- អាជ្ញាធរខេត្តគួរតែផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយប្រកបដោយតម្លាភាពអំពី ផែនការផ្តល់ដីសម្បទានសង្គមកិច្ច ដោយបង្ហាញពីទីតាំង ផែនការយុទ្ធសាស្ត្រលក្ខខណ្ឌនៃសម្បទានសង្គមកិច្ច និងការធានាសិទ្ធិកម្មសិទ្ធិ។
- គួរដោះស្រាយដីជាថ្នូរនៃដីប៉ះពាល់ជូនប្រជាពលរដ្ឋឱ្យសមរម្យ យុត្តិធម៌ ដែលអាចទទួលយកបាន ។
- អាជ្ញាធរខេត្ត គួរតែរៀបចំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ទឹកស្អាត មណ្ឌលសុខភាព សាលារៀន និង ជំនាញមុខរបរការងារនៅតំបន់ផ្តល់សម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋ ។
- រាជរដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធ គួរតែធ្វើការពិគ្រោះយោបល់ និងវាយតំលៃផលប៉ះពាល់ឱ្យបានច្បាស់លាស់ និងត្រឹមត្រូវដោយមានការចូលរួមពីប្រជាពលរដ្ឋ មុននឹងផ្តល់ដីសម្បទានសេដ្ឋកិច្ចឱ្យទៅក្រុមហ៊ុនឯកជនណាមួយ។

*អត្ថបទដោយ: បណ្តាញការងារដីធ្លី ដើម្បីអភិវឌ្ឍន៍*
*វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*

# សហគមន៍ “កំពុងតែមានការព្រួយបារម្ភ...”

ការសិក្សាអំពីបុរេសមិទ្ធិលទ្ធភាព និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានកាលពី ឆ្នាំ ២០០៩ ព្រមទាំងផ្តល់ឱកាសដល់ស្ថាប័នជំនាញរបស់រដ្ឋាភិបាល និង អង្គការសង្គមស៊ីវិលពាក់ព័ន្ធធ្វើការពិនិត្យ និង ផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង សង្គម។ ជាពិសេសលើការតាំងទីលំនៅឋានថ្មីរបស់គម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីសេសានក្រោម ២ ក្នុងសមត្ថភាពផលិតអគ្គិសនី ៤០០មេហ្គាវ៉ាត់ ដែលមានទីតាំងសាងសង់លើផ្ទៃទន្លេសេសានផ្នែកខាងក្រោម ត្រង់ចំនុចប្រសព្វនៃទន្លេសេសាន និង ទន្លេស្រែពក ក្នុងឃុំភ្លុក ស្រុកសេសាន ខេត្តស្ទឹងត្រែង ដែលមានចម្ងាយប្រមាណ ២០ គីឡូម៉ែត្រ ពីទីក្រុងស្ទឹងត្រែងនោះ។ ការសិក្សានេះ បានបញ្ចប់ទៅក្រោមការភ័យខ្លាច និង ព្រួយបារម្ភពីសំណាក់សហគមន៍ទទួលរងផលប៉ះពាល់។

ជាលទ្ធផល បានរកឃើញថាការអភិវឌ្ឍន៍គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ នឹងបង្កឱ្យមានផលប៉ះពាល់ជាចម្បងទៅលើបរិស្ថានធម្មជាតិនិងសង្គមនៅកំឡុងពេលសាងសង់ និង ប្រតិបត្តិការគម្រោង[១]។ ការប៉ះពាល់នេះអាចមានដូចជា ការបាត់បង់ធនធានជលផល ព្រៃឈើ លំនៅឋាន ដីកសិកម្ម ដំណាំ



រូបភាពរោងរបស់ក្រុមហ៊ុនរក្សាដី ថ្ម រក្សាទុកធ្វើពិសោធន៍



រូបភាពទីតាំងតួទំនប់វារីអគ្គីសនីកាត់ទន្លេសេសាន២

[១] ព័ត៌មានលំអិត ស្តីពីផលប៉ះពាល់បរិស្ថានធម្មជាតិ និងសង្គម មានអត្ថាធិប្បាយនៅក្នុងរបាយការណ៍ស្តីពីការវាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គម សំរាប់គម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីសេសានក្រោម ២។

គុណភាពទឹក និងទីកន្លែងប្រពៃណីវប្បធម៌របស់ជនជាតិដើមភាគតិច ហើយក៏អាចបង្កឱ្យមានការប្រែប្រួលប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់ ជាពិសេសប៉ះពាល់យ៉ាងខ្លាំងទៅលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដែលពឹងអាស្រ័យលើមុខរបរនេសាទ ធ្វើស្រែចំការ ផលដំណាំឈើហូបផ្លែ ការប្រើប្រាស់ទឹកទន្លេ និងផលអនុផលព្រៃឈើ។

យោងតាមលទ្ធផលនៃការប្រមូលព័ត៌មានរបស់សមាជិកបណ្តាញសម្ព័ន្ធទន្លេកម្ពុជា (RCC) ប្រចាំខេត្តស្ទឹងត្រែងបានជួបសម្ភាសន៍ជាមួយប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ និងអាជ្ញាធរមូលដ្ឋាន បានបញ្ជាក់ថាព្រៃឈើនៅក្នុងតំបន់អាងទឹកនៃគម្រោង នឹងត្រូវលិចលង់ ឬ បាត់បង់ ជាពិសេសចំការឈើជ័ររបស់ប្រជាពលរដ្ឋដែលជាប្រភពចំណូលមួយដ៏សំខាន់។ ប្រជាពលរដ្ឋចំនួនប្រមាណជាង ១៥០០គ្រួសារ (ស្ត្រីជាមេគ្រួសារប្រហែល៥%) ដែលកំពុងរស់នៅក្នុងឃុំចំនួន ៤ ក្នុងស្រុកសេសាន រួមមានឃុំតាឡាត (១ភូមិ) ឃុំក្បាលរមាស (៣ភូមិ) ឃុំភ្លុក (១ភូមិ) និងភូមិនៅក្នុងឃុំស្រែគរទាំងអស់នឹងត្រូវធ្វើការផ្លាស់ប្តូរតាំងលំនៅឋានថ្មី។ បច្ចុប្បន្នផែនការនៃការតាំងទីលំនៅឋានថ្មីនេះ អាជ្ញាធរមូលដ្ឋាន នឹងប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ដែលត្រូវផ្លាស់ប្តូរតាំងលំនៅឋានថ្មីនោះ មិនទាន់បានកំណត់ថាត្រូវរើទៅនៅកន្លែងថ្មីនៅឡើយទេ លើកលែងតែភូមិស្រែគរ១ និង ភូមិស្រែគរ២ ស្ថិតក្នុងឃុំស្រែគរប៉ុណ្ណោះ ដែលពួកគាត់បានជ្រើសរើសទីតាំងដោយខ្លួនឯង និងធ្វើសំណើសុំតំបន់តាំងទីលំនៅថ្មីតាមរយៈអង្គការដៃគូរអភិវឌ្ឍន៍ក្នុងសកម្មភាព DPA និង អាជ្ញាធរភូមិ ឃុំ ប្រចាំខេត្តស្ទឹងត្រែង។ ចំណែកឯបញ្ហាសំណងវិញ ក៏ពុំមាននរណាម្នាក់ដឹងពីគោលការណ៍នេះច្បាស់លាស់នៅឡើយដែរ។

យោងតាមការប្រជុំស្ទង់មតិប្រជាពលរដ្ឋរស់នៅក្នុងតំបន់ទទួលរងផលប៉ះពាល់ខាងលើនេះ ពួកគាត់បានលើកដៃព្រមៗគ្នាជំទាស់មិនចង់មានការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម ២ ដោយអះអាងថា ពួកគាត់ធ្លាប់ទទួលបាននូវបទពិសោធន៍មិនល្អមួយចំនួន ដែលបណ្តាលមកពីទំនប់វារីអគ្គិសនីនៅប្រទេសវៀតណាម ដូចជាការបាត់បង់ធនធានជលផល បញ្ហាទឹកកខ្វក់បណ្តាលឱ្យប្រជាពលរដ្ឋកើតជំងឺសត្វពាហនៈស្លាប់ និងការបើកទ្វារទឹកខ្លាំងបណ្តាលឱ្យមានគ្រោះថ្នាក់លិចលង់ ហើយទំនប់វារីអគ្គិសនីនោះមានទីតាំងនៅឆ្ងាយពីសហគមន៍ផង។ ចំណែកឯទំនប់វារីអគ្គិសនីសេសានក្រោម២ វិញ មានទីតាំងនៅជិតភូមិសហគមន៍រស់នៅ ដែលអាចធ្វើឱ្យមានភាពប៉ះពាល់ធ្ងន់ធ្ងរជាងករណីទំនប់វារីអគ្គិសនីនៅប្រទេសវៀតណាម ហើយតម្រូវឱ្យមានការផ្លាស់ប្តូរលំនៅឋានថ្មី រួមទាំងការបាត់បង់ទ្រព្យសម្បត្តិ ផ្ទះ សម្បែង និង ដំណាំផ្សេងទៀតផង។



ផ្ទះប្រជាពលរដ្ឋភូមិស្រែគរ១ ដែលនឹងត្រូវតាំងទីលំនៅឋានថ្មី

បច្ចុប្បន្នពួកគាត់បានសម្តែងការភ័យខ្លាចនិងព្រួយបារម្ភជាខ្លាំងទៅលើទីកន្លែងនៃការតាំងទីលំនៅឋានថ្មី ដែលមិនដឹងពិតប្រាកដថានៅកន្លែងណា នឹងអាចជាតំបន់ដែលប្រកបមុខរបរកសិកម្មបានឬទេ? ទីតាំងថ្មីអាចមានភាពក្តៅហួតហែងគ្មានម្លប់ គ្មានដំណាំឈើហូបផ្លែ ពុំមានទឹកស្អាតគ្រប់គ្រាន់សំរាប់ហូប និងប្រើប្រាស់ ដែលធ្វើឱ្យមានភាពប្រឈមទៅនឹងជំងឺផ្សេងៗ ជាពិសេសជម្ងឺរាគ ការបាត់បង់មុខរបរដោយគ្មានជំនាញក្នុងការប្រកបមុខរបរថ្មី បាត់បង់ព្រៃឈើ ផលអនុផលព្រៃឈើ បាត់បង់ សត្វព្រៃ មច្ឆា និងបាត់បង់វាលស្មៅចិញ្ចឹមគោក្របី ។ល។ ឯសម្ភារៈសំរាប់ប្រកបមុខរបរដែលមានស្រាប់ដូចជាទូក កាណូត មង អួន ត្រូវបានបោះបង់ចោលទទេផងដែរ។ ប្រជាពលរដ្ឋមួយចំនួនពុំមានកំលាំងពលកម្មដូចមុន ដោយសារខ្លួនមានវ័យចាស់ ហើយត្រូវចំណាយពេលវេលានិងថវិកាច្រើនក្នុងការសាងសង់លំនៅដ្ឋានថ្មី។ ការបាត់បង់ប្រាក់ចំណូលប្រចាំថ្ងៃអាចជះឥទ្ធិពល ធ្វើឱ្យពួកគាត់ពុំមានលទ្ធភាពឱ្យកូនទៅសាលារៀនថ្នាក់ខ្ពស់បាន ជាពិសេសទីតាំងថ្មីនេះ ស្ថិតនៅឆ្ងាយ ព្រមទាំងមិនមានហេដ្ឋារចនាសម្ព័ន្ធល្អប្រសើរ។ ពួកគាត់ព្រួយបារម្ភអំពីគោលការណ៍ ដោះស្រាយសំណងដែលមិនមានភាពយុត្តិធម៌ និង សមរម្យអាចទទួលយកបាន និងនាំឱ្យកើតមានវិវាទ។



ទិដ្ឋភាពភូមិស្រែគរ១ដែលនឹងត្រូវតាំងទីលំនៅឋានថ្មី

បញ្ហាសំណងផលប៉ះពាល់នេះ ពួកគាត់មិនទាន់ទទួលបានគោលការណ៍ដោះស្រាយនៅឡើយទេ។ ម្យ៉ាងវិញទៀត ពុំទាន់ឃើញមានក្រុមការងារណាមួយចុះទៅពិនិត្យ កត់ត្រា និង វាយតំលៃទៅលើផ្ទះ ដើមឈើ និង ផលប៉ះពាល់មុខរបរ សេដ្ឋកិច្ចសង្គម ដើម្បីទូទាត់សំណងឡើយ។

ជាទីបញ្ចប់ ដើម្បីចូលរួមចំណែកដោះស្រាយបញ្ហាខាងលើនេះ សមាជិកបណ្តាញសម្ព័ន្ធទន្លេកម្ពុជា មានអនុសាសន៍មួយចំនួនដូចជា:

- សូមឱ្យអាជ្ញាធរមានសមត្ថកិច្ចផ្សព្វផ្សាយជាសាធារណៈពីផែនការមេនៃគម្រោងរបស់ក្រុមហ៊ុនដល់ប្រជាពលរដ្ឋក្នុងសហគមន៍ទទួលរងផលប៉ះពាល់ឱ្យបានទូលំទូលាយ នឹង ជ្រាបជាព័ត៌មាន។
- ព័ត៌មានអំពីសំណងផលប៉ះពាល់គួរតែបង្ហាញឱ្យប្រជាពលរដ្ឋក្នុងសហគមន៍ទទួលរងផលប៉ះពាល់ បានដឹងមុនពេលការចាប់ផ្តើមនៃគម្រោងរបស់ក្រុមហ៊ុន។
- ការវាយតំលៃផលប៉ះពាល់គួរតែគិតគូរអំពីមុខរបរសេដ្ឋកិច្ចសង្គមរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ ដើម្បីធានាបាននូវសុខដុមនីយកម្ម។
- សំណងផលប៉ះពាល់គួរតែធ្វើឡើង ដោយប្រកាន់ភ្ជាប់នូវគោលការណ៍យុត្តិធម៌ និងសមរម្យដែលប្រជាពលរដ្ឋទទួលរងផលប៉ះពាល់អាចទទួលយកបាន។

*អត្ថបទដោយ:សមាជិកសម្ព័ន្ធទន្លេកម្ពុជា*
*វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*




**សំរាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា** ដែលបានធ្វើការបោះពុម្ពផ្សាយឯកសារស្តីពី "**ការអនុវត្តប្រសើរបំផុត ក្នុងការផ្តល់សំណង និង ការតាំងទីលំនៅថ្មីសំរាប់ទំនប់ខ្នាតធំ**" ដោយលោកអ្នក អាចទាញយកឯកសារបានតាមរយៈវ៉ែបសាយ: www.ngoforum.org.kh ឬក៏ធ្វើការទំនាក់ទំនងមកកាន់កម្មវិធីបរិស្ថាន តាមរយៈ អ៊ីម៉ែល: ngoforum@ngoforum.org.kh ។

# ស្ថានភាពជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជាត្រូវបានពិភាក្សា នៅក្នុងរបៀបវារៈនៃកិច្ចប្រជុំទីក្រុងហ្សឺណែវ

## សេចក្ដីផ្ដើម

គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍ គឺជាអ្នកជំនាញការឯករាជ្យដែលតាមដានទៅលើការអនុវត្តនូវអនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ដោយរដ្ឋភាគី [១] របស់ខ្លួន។ នៅខែធ្នូ ឆ្នាំ ២០០៩ មានរដ្ឋភាគីចំនួន ១៧៣ បានក្លាយជាប្រទេសហត្ថលេខីលើអនុសញ្ញានេះ។ ជាគោល-ការណ៍រដ្ឋភាគីទាំងអស់ត្រូវតែធ្វើរបាយការណ៍ទៅគណៈកម្មាធិការនេះ អំពីស្ថានភាពដែលសិទ្ធិកំពុងត្រូវបានអនុវត្តនៅក្នុងប្រទេសរបស់ខ្លួន។ ជាដំបូង រដ្ឋភាគីត្រូវតែធ្វើរបាយការណ៍មួយឆ្នាំបន្ទាប់ពីផ្ដល់សច្ចាប័ន ហើយបន្ទាប់មកទៀតត្រូវធ្វើរបាយការណ៍រៀងរាល់ពីរឆ្នាំម្ដង។ គណៈកម្មាធិការនេះពិនិត្យលើរបាយការណ៍នីមួយៗ ហើយបញ្ជាក់អំពីការព្រួយបារម្ភ និងអនុសាសន៍របស់ខ្លួនដល់រដ្ឋភាគីនៅក្នុងសេចក្ដីសង្ខេបផ្លូវការ។ ជារៀងរាល់ឆ្នាំ គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍បានរាយការណ៍ទៅមហាសន្និបាត ហើយផ្ដល់យោបល់ និងអនុសាសន៍ ដោយផ្អែកលើការពិនិត្យរបស់ខ្លួនទៅលើរបាយការណ៍ និងព័ត៌មាន ដែលផ្ដល់ដោយរដ្ឋភាគី។ ជាទូទៅ គណៈកម្មការនេះ ជួបប្រជុំគ្នាពីរដងក្នុង១ឆ្នាំ។ សំរាប់ឆ្នាំនេះ កិច្ចប្រជុំលើកទី៧៦ ត្រូវបានធ្វើឡើងនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ដល់ថ្ងៃទី១២ ខែមិនា ឆ្នាំ២០១០ ដោយបានអញ្ជើញភាគីរដ្ឋចំនួន១០ប្រទេស ដើម្បីធ្វើការរាយការណ៍ និងឆ្លើយបំភ្លឺនូវសំនួរផ្សេងៗដែលបានចោទសួរឡើងដោយសមាជិកទាំងអស់នៃគណៈកម្មាធិការទាក់ទងទៅនឹងស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសរបស់រដ្ឋភាគីនីមួយៗ។ ប្រទេសកម្ពុជា គឺជាប្រទេសមួយនៅក្នុងចំណោមប្រទេសទាំង១០ ដែលត្រូវបានអញ្ជើញចូលរួមនោះ។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា ក្រោមការសម្របសម្រួលជាមួយសមាជិកបណ្ដាញអង្គការគាំទ្រសិទ្ធិជនជាតិដើមភាគតិច និងសមាជិកសកម្មរបស់សិទ្ធិជនជាតិដើមភាគតិចក្រោមកិច្ចសហប្រតិបត្តិការជាមួយសម្ព័ន្ធជនជាតិដើមភាគតិចអាស៊ីអាគ្នេយ៍ បានរៀបចំរបាយការណ៍សង្ខេបជាលាយលក្ខអក្សរសម្រាប់ដាក់ជូនគណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍នៅក្នុងកិច្ចប្រជុំលើកទី៧៦ ដែលស្របតាមកាតព្វកិច្ចរបស់ខ្លួននៅក្នុងអនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍។ របាយការណ៍ដែលបានដាក់ជូននោះគឺផ្ដោតទៅលើ "សិទ្ធិរបស់ជនជាតិដើមភាគតិចនៅកម្ពុជា" ដូចដែលបានចែងនៅក្នុងមាត្រាទី១នៃអនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍។ អនុសាសន៍នៅក្នុងរបាយការណ៍នេះបានផ្ដោតជាពិសេសទៅលើបញ្ហា ដែលជនជាតិដើមភាគតិចកំពុងជួបប្រទះ ជាពិសេសបញ្ហាទាក់ទងទៅនឹងការរំលោភសិទ្ធិក្នុងការរស់នៅ និងការអាស្រ័យទៅលើសេវាសាធារណៈផ្សេងៗ ក៏ដូចជាបញ្ហាដីធ្លី និងធនធានធម្មជាតិ។



តំណាងអង្គការ និង ជនជាតិដើមភាគតិចថតរូបជាមួយគណៈប្រតិភូខ្មែរកម្ពុជាក្រោមនាសម័យប្រជុំលើកទី៧៦ ( អនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ នៅប៉ាឡែស វីលសុន ទីក្រុងហ្សឺណែវ)

[១] "រដ្ឋភាគី" មានន័យថា ប្រទេសដែលជាសមាជិកហត្ថលេខីក្នុងការទទួលស្គាល់នូវអនុសញ្ញានេះ។ ប្រទេសកម្ពុជាបានក្លាយជាសមាជិកហត្ថលេខីនៃអនុសញ្ញាអន្តរជាតិនេះ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៨៣។ ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រង់មាត្រាទី៣១ ក៏បានលើកឡើងផងដែរស្ដីពីការធានាការពារអនុសញ្ញានេះ និងសន្ធិសញ្ញាសិទ្ធិមនុស្សដទៃទៀត ថាជាផ្នែកមួយនៃច្បាប់ជាតិកម្ពុជា។

តំណាងដែលអញ្ជើញមកពីប្រទេសកម្ពុជា ដែលដឹកនាំដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានជួបជាមួយសមាជិករបស់គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍ និងបានបង្ហាញព័ត៌មានបន្ថែមស្តីពីបញ្ហារើសអើងពូជសាសន៍នៅកម្ពុជា ក៏ដូចជាបានបង្កើតទំនាក់ទំនងរវាងសង្គមស៊ីវិលកម្ពុជា និងយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដើម្បីធ្វើឱ្យយន្តការទាំងនោះមានការជាប់ទាក់ទងជាមួយប្រជាពលរដ្ឋពិតប្រាកដ និងធ្វើឱ្យអ្នកចូលរួមជាសង្គមស៊ីវិលអាចភ្ជាប់បណ្តាញសង្គមស៊ីវិលអោយកាន់តែទូលំទូលាយនៅក្នុងការតស៊ូមតិជុំវិញបញ្ហាទាំងនោះ។

តាមរយៈដំណើរការនេះ សង្គមស៊ីវិលសង្ឃឹមថានឹងមានការពង្រឹង និងការជំរុញឱ្យមានការគោរពសិទ្ធិដីធ្លី ជាពិសេសរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តវិធានការណ៍ការពារបណ្តោះអាសន្នទៅលើដីរបស់ជនជាតិដើមភាគតិច ក៏ដូចជាការជំរុញឱ្យមានការទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិច ជានីតិបុគ្គលឱ្យបានឆាប់រហ័ស ហើយស្របពេលនេះដែរក៏គួរមានការជំរុញឱ្យមានការដោះស្រាយវិវាទដីធ្លីនៅក្នុងតំបន់ជនជាតិដើមភាគតិចផងដែរ។ ជាក់ស្តែងរបាយការណ៍ផ្លូវការរបស់គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍ដែលបានមកពីអង្គការសហប្រជាជាតិ បានដាក់ទម្ងន់ក្នុងការអះអាងថា សិទ្ធិដីធ្លី មិនត្រូវបានគោរពឡើយ ហើយអាចជំរុញឱ្យធនាគារពិភពលោកគាំទ្របញ្ឈប់កម្មវិធីការកាត់បន្ថយភាពក្រីក្រ និងកម្មវិធីកាត់បន្ថយភាពក្រីក្រ និង ប្រតិបត្តិការដើម្បីកំណើន (PRGO)[២] ដែលអាចជាសារមួយដ៏មានសារៈសំខាន់សំរាប់រដ្ឋាភិបាល និងម្ចាស់ជំនួយដទៃទៀត ( PRGO ប្លូករួមទាំងសម្បទានសេដ្ឋកិច្ច)។ ដូចនេះគណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍ នឹងជួយផ្សព្វផ្សាយនូវបញ្ហាអភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជាឱ្យកាន់តែទូលំទូលាយ។

## កិច្ចប្រជុំនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស

នៅថ្ងៃទី១៥-១៩ ខែកុម្ភៈ ២០១០ គឺជាកាលបរិច្ឆេទសំរាប់ប្រទេសកម្ពុជា ក្នុងនោះអង្គការសង្គមស៊ីវិលដែលមកពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច និងតំណាងជនជាតិដើមភាគតិចបានចូលរួមអង្កេតទៅលើការពិនិត្យឡើងវិញរបស់កម្ពុជា ដែលបានធ្វើឡើងរវាងសមាជិកគណៈកម្មាធិការចំនួន១៨រូប និងរដ្ឋភាគីកម្ពុជា ដែលមានតំណាងឯកអគ្គរាជទូតប្រទេសកម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិ និងសហការីនៅក្នុងកិច្ចប្រជុំលើកទី៧៦របស់គណៈកម្មការលុបបំបាត់ការរើសអើងពូជសាសន៍នៅវិមាន Palais Wilson ទីក្រុងហ្សឺណែវ។

គណៈប្រតិភូមកពីអង្គការមិនមែនរដ្ឋាភិបាល និងតំណាងជនជាតិដើមភាគតិចបានប្រើប្រាស់ឱកាសនៃការទទួលទានអាហារថ្ងៃត្រង់ ដើម្បីជួបប្រជុំ និងបានធ្វើការសង្ខេបរបាយការណ៍របស់សង្គមស៊ីវិលទៅឱ្យអ្នកជំនាញការរបស់គណៈកម្មាធិការនេះ ក៏ដូចជាបានជួបជាមួយអ្នករាយការណ៍ពិសេសគឺ លោក **Pierre Richard Prosper** ដោយលោក បានមានការចាប់អារម្មណ៍ទៅលើស្ថានភាពរបស់ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា ដូចជាបញ្ហាការអប់រំ ហេដ្ឋារចនាសម្ព័ន្ធ បញ្ហាសុខភាព និងបញ្ហាធ្ងន់ធ្ងរជាច្រើនទៀតទាក់ទងនឹងដីធ្លី និងធនធានធម្មជាតិ។ របាយការណ៍បានបញ្ជាក់ថា ដីរបស់ជនជាតិដើមភាគតិច កំពុងតែត្រូវបានគេដកហូត ហើយជាញឹកញាប់មិនមានការពិគ្រោះយោបល់ ឬមានការពិគ្រោះយោបល់តិចតួចប៉ុណ្ណោះ ដែលធ្វើឱ្យធនធានព្រៃឈើដែលពួកគេពឹងអាស្រ័យនោះកំពុងតែត្រូវបានគេរឹបអូសយក ហើយធនធានទឹក ដែលពួកគេពឹងអាស្រ័យកំពុងតែត្រូវបានបំផ្លិចបំផ្លាញ រឺធ្វើអោយមានការខូចខាតដោយការបំពុលពីគម្រោងអភិវឌ្ឍន៍ផ្សេងៗ។

[២] PRGO: Poverty Reduction and Growth Operation: កម្មវិធីការកាត់បន្ថយភាពក្រីក្រ និងប្រតិបត្តិការដើម្បីកំណើន។



កិច្ចប្រជុំជាមួយអ្នករាយការណ៍ពិសេសសម្រាប់សិទ្ធិក្នុងការមានលំនៅឋានសមស្រប



ការបង្ហាញពីស្ថានភាពនានារបស់ជនជាតិដើមភាគតិចទៅកាន់សមាជិកគណៈកម្មាធិការទាំងមូល

តំណាងសង្គមស៊ីវិល ដែលដឹកនាំដោយលោក **ប៉ែន រង្សី** អ្នកគ្រប់គ្រងកម្មវិធីដីធ្លី និងជីវភាពរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា លោក **ជិន ថាវ៉ូ** អ្នកសម្របសម្រួលនៃអង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច និងតំណាងសហគមន៍ជនជាតិដើមភាគតិច៣រូបទៀត (លោក **អ៊ី ម៉ិច** តំណាងជនជាតិដើមភាគតិចគួយ លោក **រម៉ាម ហ៊ីល** តំណាងជនជាតិដើមភាគតិចចារ៉ាយ កញ្ញា **ខាន ចន្ធី** តំណាងជនជាតិដើមភាគតិចព្នង) បានធ្វើការណែនាំអំពីបញ្ហានៃស្ថានភាពជនជាតិដើមភាគតិចនៅកម្ពុជា ជាពិសេសបញ្ហាធ្ងន់ធ្ងរនានាដែលពាក់ព័ន្ធនៅនឹងបញ្ហាដីធ្លី និងធនធានធម្មជាតិ នៅក្នុងអង្គប្រជុំនៅថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១០។ លើសពីនេះទៅទៀត តំណាងសហគមន៍ក៏បានលើកឡើងផងដែរនូវករណីសិក្សាជាក់លាក់នានាដែលកំពុងត្រូវបានគំរាមកំហែងនៅក្នុងពេលបច្ចុប្បន្ននេះ ដូចជាបញ្ហារំលោភដីធ្លីរបស់អ្នកមានអំណាចនៅឃុំគងយុ ខេត្តរតនគិរី បញ្ហាសម្បទានដីសំរាប់ចំការកៅស៊ូនៅខេត្តមណ្ឌលគិរី បញ្ហាសម្បទានដី សំរាប់ចំការកៅស៊ូនៅស្រុកស្នួល ខេត្តក្រចេះ បញ្ហាសម្បទានរ៉ែនៅស្រុករវៀង ខេត្តព្រះវិហារ បញ្ហាដីសម្បទានសេដ្ឋកិច្ចនៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ព្រមទាំងបញ្ហាផ្សេងៗមួយចំនួនទៀត។ ឆ្លៀតក្នុងឱកាសនៃការប្រជុំនោះ តំណាងសង្គមស៊ីវិលបានស្នើសុំតាមរយៈអង្គប្រជុំថា (១) ច្បាប់ភូមិបាល គួរតែត្រូវបានគោរពឱ្យបានម៉ឺងម៉ាត់ ៖ សិទ្ធិរបស់ជនជាតិដើមភាគតិចដែលចែងក្នុងសន្ធិសញ្ញាអន្តរជាតិ និងច្បាប់ជាតិនានា ត្រូវតែគោរព (២) តុលាការ អាជ្ញាធរ និងកងកំលាំងប្រដាប់អាវុធ គួរតែការពារជនជាតិដើមភាគតិច ហើយត្រូវទទួលខុសត្រូវរាល់ការខកខានកាតព្វកិច្ចរបស់ខ្លួនក្នុងការការពារជនជាតិដើមភាគតិច (៣) ជនជាតិដើមភាគតិច និងប្រជាជនកម្ពុជាដទៃទៀត គួរតែត្រូវបានអនុញ្ញាតិឱ្យមានការចូលរួមនៅក្នុងការធ្វើការសំរេចចិត្ត និងនៅក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យបានពេញលេញ និងស្មើភាពគ្នា។ លើសពីនេះទៀត ការចូលរួមគួរធ្វើដើម្បីជាផលប្រយោជន៍របស់សហគមន៍ និងគាំទ្រអោយកាន់តែប្រសើរឡើងដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច របស់ប្រទេសជាតិ។

ស្ថានភាពជាក់លាក់ដែលពាក់ព័ន្ធទៅនឹងការបារម្ភរបស់ជនជាតិដើមភាគតិច ត្រូវបានចោទសួរទៅកាន់រដ្ឋាភិបាលកម្ពុជាដោយអ្នករាយការណ៍ពិសេស ដែលនៅក្នុងសំណួរទាំងនោះ រដ្ឋាភិបាលកម្ពុជាបានឆ្លើយថា (ប្រទេសកម្ពុជាមានប្រព័ន្ធតុលាការ ហើយប្រព័ន្ធតុលាការទាំងនោះត្រូវបានពង្រឹងដោយការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដូចនេះហើយ បញ្ហាដែលពាក់ព័ន្ធនឹងដីធ្លីនៅក្នុងតំបន់ដែលជនជាតិដើមភាគតិចរស់នៅ ត្រូវបានដោះស្រាយប្រកបដោយភាពជោគជ័យ។ លើសពីនេះទៅទៀតនោះ ប្រទេសកម្ពុជាជាប្រទេសនីតិរដ្ឋដែលមានច្បាប់ ២៤០ ត្រូវបានអនុម័ត និងប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ។




ក្រុមសមាជិកត្រួតពិនិត្យឡើងវិញរបស់អនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍

ឯកឧត្តម **ស៊ុន សួន** អ្នកតំណាងអចិន្ត្រៃយ៍របស់ប្រទេសកម្ពុជានៅការិយាល័យអង្គការសហប្រជាជាតិក្នុងទីក្រុងហ្សឺណែវ បានដឹកនាំគណៈប្រតិភូកម្ពុជា និងបានពន្យល់ថា គាត់បានទទួលស្គាល់ និងយល់ថាមានបញ្ហាទំនាស់ដីធ្លីជាច្រើនបានកើតមានឡើងដោយសារតែការលូតលាស់ផ្នែកសេដ្ឋកិច្ច ប៉ុន្តែរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ និងចាត់វិធានការណ៍ដោះស្រាយ។ ទោះជាយ៉ាងណាក៏ដោយរាជរដ្ឋាភិបាលបានប្រឈមមុខជាមួយបញ្ហាថ្មីៗជាច្រើន ដោយសារតែនិន្នាការនៃការអភិវឌ្ឍសេដ្ឋកិច្ចនេះ។

នៅចុងបញ្ចប់នៃកិច្ចប្រជុំពិនិត្យឡើងវិញ លោក **Prosper** បានធ្វើការសន្និដ្ឋានដោយលើកឡើងពីការព្រួយបារម្ភនៃការបំភិតបំភ័យ និងអំពើហិង្សាប្រឆាំងនឹងជនជាតិដើមភាគតិច នៅក្នុងអំឡុងពេលនៃការបណ្តេញចេញដោយបង្ខំ ឬ នៅក្នុងវិវាទដីធ្លី។ គាត់ក៏ព្រួយបារម្ភផងដែរទាក់ទងទៅនឹងទំនោរក្នុងការចោទប្រកាន់ និងចាប់ខ្លួនជនជាតិដើមភាគតិច នៅពេលដែលពួកគេប្រឆាំងទៅនឹងការបណ្តេញចេញដោយបង្ខំ ឬប្រឆាំងទៅនឹងការផ្តល់សម្បទាននៅលើដីរបស់ជនជាតិដើមភាគតិច។ លើសពីនេះទៅទៀត គាត់បានឱ្យយោបល់ថា រាជរដ្ឋាភិបាលកម្ពុជាត្រូវតែធានាឱ្យមានយុត្តិធម៌ និងតម្លាភាព នៅក្នុងដំណើរការផ្តល់ដីសម្បទានសេដ្ឋកិច្ចតាមរយៈការចូលរួមពីក្រុមជនជាតិដើមភាគតិចដែលរស់នៅទីនោះ ដើម្បីធានាអោយមានស្ថេរភាព និងការយកចិត្តទុកដាក់ទៅលើជនជាតិដើមភាគតិចប្រកបដោយសមភាព។

## សេចក្តីសន្និដ្ឋាន

ការត្រួតពិនិត្យឡើងវិញនៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍មានសារៈសំខាន់ណាស់ ដោយសារតែដំណើរការនេះបានធ្វើឱ្យប្រតិភូសង្គមស៊ីវិល ជាពិសេសអង្គការមិនមែនរដ្ឋាភិបាល និង តំណាងជនជាតិដើមភាគតិច បានធ្វើសេចក្តីថ្លែងការណ៍ផ្ទាល់មាត់ទៅកាន់គណៈកម្មាធិការនេះក្នុងអំឡុងពេលនៃកិច្ចប្រជុំ។ ក្រៅពីនេះ តំណាងសង្គមស៊ីវិលនេះ បានធ្វើការអង្កេតទៅលើដំណើរការដែលត្រូវបានធ្វើឡើងដោយសមាជិករបស់គណៈកម្មាធិការទាំងអស់ ក៏ដូចជាបានស្តាប់ឮនូវការឆ្លើយតបរបស់គណៈប្រតិភូរដ្ឋាភិបាលដែលបង្ហាញពីបញ្ហានៅក្នុងប្រទេសកម្ពុជា។

អង្គការមិនមែនរដ្ឋាភិបាល និងតំណាងជនជាតិដើមភាគតិច បានពង្រីកសកម្មភាពតស៊ូមតិ នៅក្នុងអំឡុងពេលនៃបេសកកម្មតាមរយៈទស្សនៈកិច្ចនៅការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ជាពិសេសផ្នែកទាក់ទង នឹងគោលនយោបាយពិសេស ដូចជាអ្នករាយការណ៍ពិសេសទទួលបន្ទុក

សិទ្ធិក្នុងការមានលំនៅឋានសមស្រប អ្នករាយការណ៍ពិសេសដើម្បីការពារសិទ្ធិមនុស្ស អ្នករាយការណ៍ពិសេស ដើម្បីសិទ្ធិជនជាតិដើម និងជនជាតិភាគតិច និងសហព័ន្ធខ្មែរកម្ពុជាក្រោម ។

ដោយឡែកក្នុងអំឡុងពេលប្រជុំត្រួតពិនិត្យឡើងវិញ អង្គការមិនមែនរដ្ឋាភិបាល និងតំណាងជនជាតិដើមភាគតិច មានការសោកស្តាយយ៉ាងខ្លាំង ដោយសារតែគណៈប្រតិភូរាជរដ្ឋាភិបាលដែលទៅចូលរួមក្នុងការពិភាក្សាលើអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍នោះមិនមានវត្តមានតំណាងក្រសួងជំនាញ ឬការិយាល័យពាក់ព័ន្ធនានា ដែលមកពីប្រទេសកម្ពុជាឡើយ ពោលគឺមានតែតំណាងឯកអគ្គរាជទូតកម្ពុជាដែលប្រចាំការនៅទីនោះប៉ុណ្ណោះ ។ ជាក់ស្តែងប្រតិភូរាជរដ្ឋាភិបាលដែលមានវត្តមាននោះ មិនបានឆ្លើយតបឱ្យបានច្បាស់លាស់ទៅនឹងសំនួរដែលលើកឡើងដោយគណៈកម្មាធិការឡើយ ជាពិសេសទាក់ទងនឹងការព្រួយបារម្ភអំពីការផ្តល់ដីសម្បទានសេដ្ឋកិច្ចយ៉ាងដែលមានទំហំធំៗនៅប្រទេសកម្ពុជា ដែលប៉ះពាល់យ៉ាងខ្លាំងដល់មុខរបរប្រពៃណី និងវប្បធម៌របស់ជនជាតិដើមភាគតិច ក៏ដូចជាអំពើហិង្សាទៅលើជនជាតិដើមភាគតិចក្នុងអំឡុងពេលមានការបណ្តេញចេញ ដោយបង្ខំ និងបញ្ហាវិវាទដីធ្លី ។ ទោះបីជាយ៉ាងណាក៏ដោយការអប់រំ និងសុខភាព ក៏ជាបញ្ហាដែលមានការព្រួយបារម្ភ និងលើកជាសំនួរផងដែរ ដោយសមាជិកគណៈកម្មាធិការ ប៉ុន្តែសំនួរទាំងអស់នេះ មិនត្រូវបានឆ្លើយតបឱ្យបានច្បាស់លាស់ដោយឯកអគ្គរាជទូត ក៏ដូចជាសហការីឡើយ ។

*អត្ថបទដោយៈ លោក ប៉ែន រង្សី*
*អ្នកគ្រប់គ្រង កម្មវិធីដីធ្លី និងជីវភាព*
*វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*




**សំរាប់ព័ត៌មានបន្ថែមសូមទំទាក់ទំនងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**
ដែលបានធ្វើការបោះពុម្ពផ្សាយឯកសារស្តីពី "**សិទ្ធិជនជាតិដើមភាគតិចនៅកម្ពុជា**"
ដោយលោកអ្នកអាចទាញយកឯកសារបានតាមរយៈវេបសាយៈ www.ngoforum.org.kh
ឬក៏ធ្វើការទំនាក់ទំនងមកកាន់កម្មវិធីដីធ្លី និងជីវភាព តាមរយៈ
អ៊ីម៉ែលៈ ngoforum@ngoforum.org.kh ។

# សហគមន៍ព្រៃឈើ នៅឃុំអូរគ្រៀង

ក្រុមហ៊ុនកូរ៉េមួយឈ្មោះ CENTRAL FIRST COMPANY LIMITED បានទទួលសិទ្ធិ ពីរាជរដ្ឋាភិបាលកម្ពុជា ផ្តល់ដីសម្បទានទំហំ ១០.០០០ហិកតា តាមរយៈលិខិត សជណ លេខ ១២៨៦ ចុះ ថ្ងៃទី ១០-១០-២០០៨ ដោយទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីអភិវឌ្ឍន៍ដាំដំណាំកៅស៊ូ។ នៅក្នុងអំឡុង ខែមេសា ឆ្នាំ២០០៩ ក្រុមហ៊ុន បាននាំគ្រឿងចក្រចូល និងឈូសឆាយដី ដោយមានកងកម្លាំងរបស់តំបន់ប្រតិបត្តិការសឹក ខេត្តក្រចេះ ចំនួន ៦នាក់ និងប្រដាប់ដោយអាវុធគ្រប់ដៃផង ជាអ្នកការពារគ្រឿងចក្រទាំងនោះ។

ប្រតិកម្មទៅនឹងគ្រឿងចក្រទាំងនោះ ប្រជាពលរដ្ឋជនជាតិដើមភាគតិច ចំនួន០៤ ភូមិ ប្រមាណជាង ៣០០ គ្រួសារ[១] ស្ថិតនៅក្នុងឃុំអូរគ្រៀង ស្រុកសំបូរ មានការព្រួយបារម្ភជាខ្លាំងចំពោះ ដីស្រែ ដីចំការ ចំការវិលជុំ ព្រៃសហគមន៍ ព្រៃតំណម និងទីកន្លែងសំរាប់ឃ្វាលគោ ក្របីរបស់ពួកគាត់ ។

នៅក្នុងឃុំ អូរគ្រៀង មានសហគមន៍ព្រៃឈើ ចំនួន ៣ គឺ សហគមន៍ព្រៃឈើ ខ្សាច់ លាវ មានផ្ទៃដីចំនួន ១.៨៦៣ ហិកតា សហគមន៍ព្រៃឈើ កោះខ្មែរ មានផ្ទៃដីចំនួន១.៦៧៨ ហិកតា និងសហគមន៍ព្រៃឈើ ពន្ទជា មានផ្ទៃដីចំនួន ៦៨៨ ហិកតា។ សហគមន៍ព្រៃឈើទាំងនេះ ដែលត្រូវបានជួយរៀបចំបង្កើតឡើងដោយអាជ្ញាធរមូលដ្ឋាន និងសង្កាត់រដ្ឋបាលព្រៃឈើ និង បានចាត់ថ្នាក់ថា ជាតំបន់សក្តានុពល តាំងពីឆ្នាំ២០០៦ ហើយបានដាក់ឯកសារសុំការទទួលស្គាល់ពីអាជ្ញាធរថ្នាក់ជាតិក្នុងឆ្នាំ២០០៧ ព្រមទាំងបានរៀបចំជាបែបបទសហគមន៍បានដល់ជំហានទី០៥ ទៀតផង។

ប្រជាពលរដ្ឋបាននាំគ្នាប្រមូលផ្តុំ ធ្វើការតវ៉ាជាមួយក្រុមហ៊ុនចំនួនពីរលើកគឺ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩ នៅពេលដែលក្រុមហ៊ុនយកគ្រឿងចក្រមកធ្វើការឈូសឆាយ ដែលធ្វើអោយប៉ះចំដីស្រែចំការ នៅភូមិស្រែចារ និង ធ្វើការតវ៉ាលើកទីពីរនៅថ្ងៃទី០៨ ឧសភា ២០០៩ នៅពេល ដែលក្រុមហ៊ុនធ្វើការឈូសឆាយដី ប៉ះចំព្រៃជំនឿ ក្នុងភូមិអូរព្រះ និង ភូមិខ្សាច់លាវ។ ការឈូសឆាយរបស់ក្រុមហ៊ុនទាំងពីរលើកនេះ មិនទាន់ធ្វើអោយមានផលប៉ះពាល់ មានទ្រង់ទ្រាយធំដុំឡើយ ដោយប្រជាពលរដ្ឋ បានធ្វើការទប់ស្កាត់ទាន់សភាពការណ៍ ខណៈពេលដែលក្រុមហ៊ុនទើបតែ ចាប់ផ្តើមធ្វើការឈូសឆាយ។ ទន្ទឹមនឹងនោះផងដែរ តំណាងសហគមន៍ បានដាក់ពាក្យបណ្តឹងទៅសង្កាត់រដ្ឋបាលព្រៃឈើ ដែលមានការិយាល័យ ស្ថិតនៅក្នុងស្រុកសំបូរ ខេត្តក្រចេះ ហើយព្រមទាំង បានសំណូមពរឱ្យមានការជួយអន្តរាគមន៍ពីអង្គការសង្គមស៊ីវិលនានា ដែលធ្វើការលើការងារសហគមន៍ព្រៃឈើ និងធនធានធម្មជាតិ ។ ក្រោយពីព័ត៌មានអំពីផលប៉ះពាល់បានទៅដល់មន្ត្រីពាក់ព័ន្ធ និងមានការអន្តរាគមន៍ពីអង្គការមិនមែនរដ្ឋាភិបាលផងនោះ យើងឃើញមានដំណើរការនៃការដោះស្រាយ ត្រូវបានធ្វើឡើងដោយមន្ត្រីពាក់ពន្ធ័មួយចំនួន តែទោះជាយ៉ាងនេះក្តី ប្រជាពលរដ្ឋនៅតែមិនទាន់អាចទទួលយកនូវលទ្ធផលនៃដំណោះស្រាយទាំងនោះបាននៅឡើយទេ។ (សូមមើលលទ្ធផលដំណើរការនៃការដោះស្រាយ) ។

[១] ភូមិខ្សាច់លាវចំនួនៈ ៦៤ គ្រួសារ ភូមិកោះខ្មែរចំនួនៈ ១៣៧ គ្រួសារ នៅភូមិពន្ទជាចំនួនៈ ១០៦ គ្រួសារ និងអ្នកភូមិអូរព្រះមួយចំនួនទៀត




ផែនទីក្រុមហ៊ុនដែលមានព្រំប្រទល់ពណ៌លឿង និងទីតាំងព្រៃសហគមន៍ទាំងបីនៅខាងក្នុង

ក្រុមការងារបណ្តាញជីវភាពអាស្រ័យព្រៃឈើ និងចំការឈើដាំរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានសហការជាមួយអង្គការវីកូស អង្គការអាដហុក និងអង្គការសេដ ដែលមានការិយាល័យ នៅខេត្តក្រចេះ បានធ្វើការប្រជុំពិភាក្សា និងចែករំលែកព័ត៌មាននៅថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១០ ហើយក្រុមការងាររបស់បណ្តាញព្រៃឈើ បានចុះទៅជួបជាមួយសហគមន៍ នៅក្នុងឃុំអូរគ្រៀង និងអាជ្ញាធរពាក់ពន្ធ័ នៅថ្ងៃទី ១៦-១៧ ខែមីនា ឆ្នាំ ២០១០ ដើម្បីប្រមូលព័ត៌មានបន្ថែមអំពី (ក) ផលប៉ះពាល់នៅសហគមន៍ (ខ) ដំណើរការនៃការដោះស្រាយ និង (គ) ជំរុញអោយអាជ្ញាធរមានសមត្ថកិច្ចពន្លឿនការដោះស្រាយជូនប្រជាពលរដ្ឋ ។

មន្ត្រីអាជ្ញាធរមូលដ្ឋាន ក៏ដូចជាសមាជិកអង្គការដៃគូអភិវឌ្ឍន៍ ដែលមានតំបន់គោលដៅ ក្នុងឃុំអូរគ្រៀង បានបញ្ជាក់ថា ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម និងការផ្តល់ព័ត៌មានអំពីគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន **សិនត្រល់ហ្វឺស** (Central First Company) នេះមិនបានធ្វើដោយត្រឹមត្រូវឡើយ ។ សិទ្ធិអំណាចរបស់អាជ្ញាធរមូលដ្ឋានក្នុងការចូលរួមក្នុងកិច្ចអភិវឌ្ឍន៍ផ្សេងៗ និងការសំរេចចិត្ត មិនត្រូវបានផ្តល់អោយដោយពេញលេញនៅឡើយ ។ ការវាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គមសំរាប់ក្រុមហ៊ុនសិនត្រល់ហ្វឺសនេះ គឺអាជ្ញាធរថ្នាក់លើជាអ្នកចុះមកធ្វើដោយផ្ទាល់តែម្តងខាងឃុំ គ្រាន់តែត្រូវបានអញ្ជើញអោយចូលរួមប៉ុណ្ណោះ ហើយក្រុមហ៊ុន មិនបានតំកល់ទុកឯកសាររបស់គេនៅក្នុងឃុំទេ គឺក្រុមហ៊ុនធ្វើការតែជាមួយថ្នាក់ខេត្ត ប៉ុណ្ណោះ ។

ឃុំអូរគ្រៀង មានភូមិចំនួន ៦ ដែលមានប្រជាពលរដ្ឋគិតមកដល់ ឆ្នាំ ២០០៩ នេះ សរុប ១.២៤២ គ្រួសារ ស្មើ ៨.១៧៤ នាក់ (ស្ត្រី ២.៦៥៩ នាក់) ។ ដែនដីរដ្ឋបាលរបស់ឃុំ មាន ៩២៧ គីឡូម៉ែត្រការ៉េ គឺស្មើ ៩២.៧០០ ហិកតា ដែលក្នុងនោះ មានទាំងដីស្រែជាក់ស្តែង ៩១៥ ហិកតា ដីចំការ ជាក់ស្តែង ២៥៦ ហិកតា ព្រៃដៃគូរ ៣.១៦៤ ហិកតា ព្រៃសហគមន៍ចំនួនបី ស្មើ ៤.២២៩ ហិកតា ក្រៅពីនេះមានចំការវិលជុំ និងព្រៃតំណមមួយចំនួនទៀត ។

នៅក្នុងឃុំអូរគ្រៀងមានក្រុមហ៊ុន ចំនួន ៥ ដែលបានទទួលដីសម្បទានសេដ្ឋកិច្ចពីរាជរដ្ឋាភិបាលគឺ:

- ក្រុមហ៊ុន វៀតណាមដាំកៅស៊ូចំនួន ២
- ក្រុមហ៊ុន GLOBAL ដាំដើមម៉ៃសាក់ចំនួន ១
- ក្រុមហ៊ុនគ្រីនវិនជីរបស់ចិន ដាំដើមម៉ៃសាក់ ចំនួន ១
- ក្រុមហ៊ុន សិនត្រល់ហ្វឺស ដាំកៅស៊ូ ចំនួន ១ អាជ្ញាធរឃុំបានឱ្យដឹងថា បើតាមគម្រោងរបស់ ក្រុមហ៊ុន ដីព្រៃ ក្នុងឃុំស្នើរ

តែទាំងអស់ នឹងត្រូវធ្វើការឈ្លូសឆាយ ដោយក្រុមហ៊ុនទាំង ៥ នេះ ប៉ុន្តែឥឡូវនេះ នៅក្នុងឃុំ មិនមានដីសំរាប់ដោះស្រាយជូនប្រជាពលរដ្ឋទៀតឡើយ ។

## លទ្ធផលនៃដំណើរការដោះស្រាយ

**លើកទី១-** មន្ត្រីក្រុមការងារដោះស្រាយវិវាទដីធ្លីរបស់សាលាខេត្ត បានចុះធ្វើការវាយតំលៃ ដោយសហការពីអាជ្ញាធរមូលដ្ឋាន និងបានទទួលយកសំណើពីសហគមន៍ ដើម្បីសុំសេចក្តីសំរេចពីគណៈអភិបាលខេត្ត ក្រោយមក ខេត្តបានសំរេចកាត់ដី ទំហំ ៣.០០០ ហិកតា ទុកឱ្យប្រជាពលរដ្ឋវិញ ដោយយោងតាមរបាយការណ៍របស់ក្រុមការងារសាលាខេត្ត និងសំណូពររបស់ប្រជាពលរដ្ឋ។ ទោះជាយ៉ាងនេះក្តី ប្រជាពលរដ្ឋទាំង ៤ភូមិ នេះនៅតែមិនទាន់យល់ព្រម ព្រោះទំហំដីរបស់ក្រុមហ៊ុនចំនួន ៧.០០០ ហិកតា[២]នេះ បានរំលោភយកដីព្រៃសហគមន៍ដីចំការវិលជុំដីព្រៃតំណមរបស់ពួកគាត់ទាំងអស់។

**លើកទី២-** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានចុះមកធ្វើការសំរុះសំរួល ដោយមានការចូលរួមពីមន្ត្រីសាលាខេត្ត និងអភិបាលរងខេត្តផង ពេលនោះប្រជាពលរដ្ឋបានបង្ហាញជូន ឯកឧត្តមទេសរដ្ឋមន្ត្រី អំពីផែនទីព្រៃឈើសហគមន៍ទាំងបីនៅក្នុងភូមិ ដែលត្រូវទទួលស្គាល់ពីរដ្ឋបាលព្រៃឈើ។ ជាលទ្ធផលនៃការសំរុះសំរួល លោកអភិបាលរងខេត្ត បានសំរេចកាត់ដីទំហំត្រឹមតែ ៩២៧ ហិកតា ប៉ុណ្ណោះ សំរាប់ទុកឱ្យប្រជាពលរដ្ឋចំនួន៣ភូមិ ដើម្បីប្រើប្រាស់ធ្វើស្រែចំការ[៣] ដែលសេចក្តីសំរេចនេះផ្ទុយគ្នាទាំងស្រុងទៅនឹងសេចក្តីសំរេចរបស់ឯកឧត្តមអភិបាល (លើកទី១) ។

**លើកទី៣-** ប្រជាពលរដ្ឋតំណាងសហគមន៍ព្រៃឈើចំនួន ៧នាក់ មកពីសហគមន៍ អូរព្រះខ្សាច់លាវ និងពន្ទជា រួមទាំងមេភូមិផង ត្រូវបានអញ្ជើញឱ្យចូលមកដោះស្រាយ នៅសាលាខេត្ត ដោយមានរថយន្តខាងក្រុមហ៊ុនមកដឹកដល់ភូមិ។ តំណាងសហគមន៍ដែលត្រូវបានអញ្ជើញអោយចូលរួមដោះស្រាយវិវាទនោះ មិនបានដឹងអ្វីជាលទ្ធផលនៃការដោះស្រាយនោះឡើយ ពួកគាត់គ្រាន់តែចាំថា " គេអោយពួកគាត់ចូលជួបម្តងម្នាក់ៗ ហើយប្រាប់ថា កុំជឿពួកអង្គការខ្លាំងពេក បើពួកអង្គការអាចជួយពួកគាត់ អោយរួចពីខ្នោះបានសូមជឿចុះ ហើយជាចុងក្រោយពួកគាត់ ត្រូវបាននាំទៅកំសាន្តសប្បាយនៅប្រទេសវៀតណាម ដោយមានការគាំទ្រថវិកាសំរាប់ការធ្វើដំណើរ ការហូបចុក និងស្នាក់នៅដោយភាគីក្រុមហ៊ុន " ចំពោះព័តិមានសំខាន់ៗអំពីលទ្ធផលនៃការដោះស្រាយនោះមិនដឹងឡើយ ។

**លើកទី៤-** នៅក្នុងអំឡុងសប្តាហ៍ ទី២ និង ទី៣ ខែមីនា ឆ្នាំ២០១០ មានតំណាងមន្ត្រីសាលាស្រុកម្នាក់ តំណាងអាជ្ញាធរឃុំម្នាក់ តំណាងភាគីក្រុមហ៊ុន និងមេភូមិ បានចុះធ្វើការវាស់វែងទុកដីចំណីផ្លូវ ពីផ្លូវថ្នល់ជាតិចូល ទៅភូមិ អូរគ្រៀង និងភូមិខ្សាច់លាវ តាមបណ្តោយផ្លូវគ្រួសក្រហម ដោយទុកដីចំណីផ្លូវប្រវែង ១៥០ម៉ែត្រ ពីអ័ក្សផ្លូវ (ស្មើ៣០០ម៉ែត្រទាំងសងខាងផ្លូវ)។ ក្រៅពីទុកដីចំណីផ្លូវ ៣០០ម៉ែត្រនេះ ក្រុមហ៊ុននេះបានវាស់កាត់ដីទីទួលដែលមានថ្ម ដែលធ្វើការដាំដុះមិនបាន និងកាត់ចេញនូវតំបន់តាមបណ្តោយមាត់ស្ទឹងមួយចំនួនទៀត។ ប្រជាពលរដ្ឋ នៅភូមិ អូរគ្រៀង និងភូមិខ្សាច់លាវ បានបញ្ជាក់ថា សកម្មភាពកាត់ដីចំណីផ្លូវ និងដីចំណីបឹង ដែលដឹកនាំដោយ ភាគីក្រុមហ៊ុននេះ ប្រហែលជាការឆ្លើយតបទៅនឹងសេចក្តីសំរេចលើកទី១ របស់ឯកឧត្តមអភិបាល ដែលសំរេចកាត់ ដីទំហំ ៣.០០០ ហិកតា អោយប្រជាពលរដ្ឋនោះហើយ។

*អត្ថបទដោយ: លោក ខៀវ ចាន់ មន្ត្រីផ្នែកច្បាប់*
*វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*

[២] ប្រភពព័តិមាន របាយការណ៍របស់វិទ្យុអាស៊ីសេរី
[៣] យោងតាមរបាយការណ៍របស់គណៈកម្មាធិការប្រព្រឹត្តកម្ម

# ការបង្កើតសហគមន៍ និងការដោះស្រាយវិវាទដីធ្លី

## ១.ទីតាំងភូមិសាស្ត្រ និងប្រវត្តិរបស់សហគមន៍

សហគមន៍កំពង់សាមគ្គី មានទីតាំងភូមិសាស្ត្រៈ ខាងជើងជាប់ស្រែអំបិល ខាងត្បូងជាប់សមុទ្រ ខាងលិចជាប់សហគមន៍ត្រពាំងសង្កែ និងខាងកើតជាប់សហគមន៍ការពារធនធានឃុំអូរក្រសារ និងមានទីតាំងស្ថិតនៅក្បែរឆ្នេរសមុទ្រ ស្ថិតនៅក្នុងភូមិកំពង់ត្នោត ឃុំកូនសត្វ ស្រុកទឹកឈូ ខេត្តកំពត។ ចំនួនគ្រួសារក្នុងសហគមន៍សរុបមាន ៧៥៩ គ្រួសារ និងមាន ៧១៧ ខ្នងផ្ទះ មានប្រជាជនសរុបចំនួន ៣៧៤៣ នាក់ ក្នុងនោះស្រី ១៩៣៧ នាក់ និងប្រុស ១៨០៥ នាក់។

សហគមន៍មានផ្ទៃដីសរុបចំនួន ៥៧៧ ហិកតា ដោយរួមបញ្ចូលទាំងដី ៧២ ហិកតា ដែលមានវិវាទ និងមានសមាជិកពេញសិទ្ធិសរុបចំនួន ៣៩៦ នាក់ ស្រី ១៣៨ នាក់។ ប្រជាពលរដ្ឋក្នុងសហគមន៍បានកាន់កាប់ដីតាំងពីឆ្នាំ២០០៦ និង អាស្រ័យផលលើដីនេះតាំងពីដូនតាមក ប៉ុន្តែសហគមន៍ពុំមានឯកសារបញ្ជាក់អំពីការកាន់កាប់ដីស្របច្បាប់ទេ ព្រោះតំបន់នោះជាសម្បត្តិសាធារណៈរបស់រដ្ឋ។ ប្រជាពលរដ្ឋបានមករស់នៅក្នុងតំបន់នេះ ដោយមានការទទួលស្គាល់ពីអាជ្ញាធរតំបន់ គ្រប់លំដាប់ថ្នាក់ ហើយសមាជិករបស់សហគមន៍ក៏មានអត្តសញ្ញាណប័ណ្ណ ៩០% មានសៀវភៅគ្រួសារ ៩៥% ចំនួនប្រជាពលរដ្ឋមានប័ណ្ណបោះឆ្នោត ៨០% និងចំនួនប្រជាពលរដ្ឋមានសំបុត្រកំណើត ៩៥%។

## ២.ការចងក្រងសហគមន៍

សហគមន៍បានចងក្រង នៅថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០០៦។ ប្រជាពលរដ្ឋនៅក្នុងភូមិបានរួមសហការគ្នាចងក្រង និងបង្កើតជាសហគមន៍ ដោយមានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធនានា មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី និងកុមារនៅកម្ពុជា (CWDCC)[១] និង អង្គការ GTZ[២] ក៏បានជួយគាំទ្រថវិកាក្នុងការបង្កើតផងដែរ។ សហគមន៍នេះ បង្កើតឡើងក្នុងគោលបំណងដើម្បីលើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជានេសាទ ឱ្យបានរីកចំរើន និងកាត់បន្ថយនូវភាពក្រីក្រ។

ស្ថាប័នអង្គការដែលជួយគាំទ្រសហគមន៍មានដូចជា :

១. មជ្ឈមណ្ឌល CWDCC ជួយគាំទ្រថវិកាក្នុងការរៀបចំ និងបង្កើតសហគមន៍ ធ្វើផែនទីគ្រប់គ្រងសហគមន៍ បោះបង្គោលកំណត់ព្រំប្រទល់សហគមន៍ កសាងទីស្នាក់ការ និងផ្ដល់សំភារៈសំរាប់ដើរល្បាតនិងអភិរក្សព្រៃកោងកាង និងបង្កើតធនាគារក្ដាមសេះ ជាដើម។

២. អង្គការ GTZ ជួយថវិការៀបចំបង្កើតសហគមន៍ និងកំណត់ព្រំប្រទល់សំរាប់ការគ្រប់គ្រង។

៣. អង្គការ UNDP[៣] ជួយផ្ដល់ថវិកាក្នុងការអភិរក្សស្មៅសមុទ្រ និងបង្កើតក្រុមសន្សំប្រាក់។

៤. អង្គការ SCW[៤] ជួយថវិកាក្នុងការពង្រឹងរចនាសម្ព័ន្ធគណៈកម្មការ និងជនបង្គោលសហគមន៍។

៥. អង្គការ CMDP ជួយផ្ដល់ថវិកាក្នុងការធ្វើដំណើរសំរាប់សហគមន៍មកជួបជុំគ្នាក្នុងតំបន់ឆ្នេរសមុទ្រ ដើម្បីផ្លាស់ប្ដូរបទពិសោធន៍ ក្នុងការចងក្រងសហគមន៍ និងធ្វើការបណ្ដុះបណ្ដាលទៅលើផ្នែកច្បាប់នានា។

៦. សមាគមធាងត្នោត ផ្ដល់ថវិកាសំរាប់ធ្វើទស្សនៈកិច្ចសិក្សាទៅលើផ្នែកអេកូទេសចរណ៍។

## ៣.ប្រវត្តិនៃវិវាទដីធ្លីរបស់សហគមន៍

តាមរបាយការណ៍របស់សហគមន៍ បានអោយដឹងថាសហគមន៍នេសាទកំពង់សាមគ្គីមានដីព្រៃកោងកាងសរុបចំនួន ៧២

---

[១] CWDCC: Children and Women Development Center in Cambodia : មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី និងកុមារនៅកម្ពុជា

[២] GTZ: German Technical Cooperation : កិច្ចសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់

[៣] UNDP: United Nation Development Program : កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ

[៤] SCW: Safe Community Wildlife : អង្គការសង្គ្រោះសត្វព្រៃ

ហិកតា ដែលមានទំនាស់កាលពី ថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០០៨ ហើយទំនាស់នេះបានកើតឡើងរវាង សហគមន៍ជាមួយនឹងមន្ត្រីកសិកម្មខេត្តកំពតចំនួន ០៤ នាក់ (សុំមិនបញ្ចេញឈ្មោះ)។ ក្រោយពេលមានវិវាទ សហគមន៍បានទទួល និងចងក្រងទុកនូវឯកសារដែលពាក់ព័ន្ធព្រមទាំងឯកសារផ្សេងៗ ដែលប្រជាពលរដ្ឋបានដាក់ប្តឹងទៅស្ថាប័នរដ្ឋាភិបាល ដូចជាប្រជាពលរដ្ឋបានដាក់ពាក្យបណ្តឹងចូលតុលាការខេត្តកំពត លិខិតស្នើសុំទៅសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ដើម្បីសុំការជួយអន្តរាគមន៍ សេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីដែលបានសំរេចប្រគល់ដីឱ្យប្រជាពលរដ្ឋ លិខិតចេញដោយសាលាខេត្តកំពតឱ្យអភិបាលស្រុកប្រគល់ដីឱ្យសហគមន៍ ទីស្តីការគណៈ រដ្ឋមន្ត្រីបានចេញលិខិតបញ្ជាក់អំពីការប្រគល់ដីឱ្យសហគមន៍ ដីកាកោះហៅរបស់តុលាការខេត្តកំពតឱ្យតំណាងប្រជាពលរដ្ឋ ចូលសវនាកា និងលិខិតបញ្ជាក់របស់អាជ្ញាធរមានសមត្ថកិច្ចដែលសំរេចប្រគល់ដីឱ្យសហគមន៍វិញ។ (ព័ត៌មានលំអិត សូមមើលនៅក្នុងឧបសម្ព័ន្ធជូនភ្ជាប់ខាងក្រោម)។

## ៤. ស្ថានភាព និងសកម្មភាពជាប្រចាំរបស់សហគមន៍

ប្រជាពលរដ្ឋ ទាំងមុន និងក្រោយពេលមានវិវាទ ប្រជាពលរដ្ឋ ៨០% ជាអ្នកនេសាទសមុទ្រ ដែលទទួលបានប្រាក់ចំណូលមធ្យម ក្នុងមួយថ្ងៃ ប្រហែល ៨០០០ រៀល។ សកម្មភាពជាប្រចាំរបស់សហគមន៍ មានដូចជាការការពារធនធានធម្មជាតិ ការអភិរក្ស ព្រៃកោងកាង ការអភិរក្សស្មៅសមុទ្រ និងការធ្វើធនាគារក្តាមសេះ។

## ៥. ទំនាក់ទំនងរវាងសហគមន៍ជាមួយស្ថាប័នផ្សេងៗ

សហគមន៍នេសាទកំពង់សាមគ្គី ធ្លាប់បានធ្វើការទំនាក់ទំនងជាមួយបណ្តាញសហគមន៍តាមឆ្នេរសមុទ្រ និងចូលរួមដាំដើមកោងកាង និង ចូលរួមជាមួយសហគមន៍ព្រៃនប់ ដាំកូនត្នោតនៅសហគមន៍ព្រៃកត្នោត។ ប្រជាពលរដ្ឋ និងតំណាងសហគមន៍មានទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់តាំងពីភូមិដល់ខេត្ត និងចូលរួមប្រជុំប្រចាំខែ ចូលរួមអនុវត្តន៍ផែនការសកម្មភាពរបស់ថ្នាក់ភូមិ និងសហគមន៍។ អាជ្ញាធរបានដឹងរាល់សកម្មភាពការងាររបស់សហគមន៍ ពីព្រោះមានទំនាក់ទំនងជាប្រចាំ។ សហគមន៍ក៏ធ្លាប់បានអញ្ជើញអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ឱ្យចូលរួមសកម្មភាពនានារបស់សហគមន៍ ដើម្បីឱ្យមានការទទួលស្គាល់អំពីកិច្ចការក្នុងសហគមន៍ និងដើម្បីបានការចូលរួមផងដែរ។

សកម្មភាព និងការងារដែលអាជ្ញាធរជួយដល់សហគមន៍មានដូចជាៈ

១. ការងារផ្សព្វផ្សាយផ្នែកច្បាប់

២. ការងារអភិរក្ស

៣. ការងារជួយបង្ក្រាបបទល្មើសនេសាទ

## ៦. ផែនការបន្តរបស់សហគមន៍នៅថ្ងៃអនាគត

ពង្រឹង និង កសាងបន្ថែមនូវធនធានមនុស្ស រៀបចំអភិវឌ្ឍន៍សហគមន៍ ដើម្បីកាត់បន្ថយភាពក្រីក្រ អភិរក្សព្រៃកោងកាងបន្ថែម។

## ៧. សំណូមពរទៅរាជរដ្ឋាភិបាលៈ

សូមឱ្យរាជរដ្ឋាភិបាលជួយគាំទ្ររាល់សកម្មភាពអភិវឌ្ឍន៍របស់សហគមន៍ ដើម្បីកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាជនដោយបណ្តុះបណ្តាលផ្នែកច្បាប់នានាបន្ថែមទៀតដល់ប្រជាពលរដ្ឋក្នុងសហគមន៍ដើម្បីបង្កើនការយល់ដឹង និងការអភិរក្សទៅលើធនធានធម្មជាតិនៅក្នុងសហគមន៍ដូចជាព្រៃលិចទឹក អភិរក្សស្មៅសមុទ្រ និងជីវចំរុះជាដើម។

## ៨. សេចក្តីសន្និដ្ឋានៈ

តាមរយៈបទពិសោធន៍របស់សហគមន៍នេសាទកំពង់សាមគ្គី ដែលបានចងក្រងទុកនេះបានបង្ហាញអំពីការអត់ធ្មត់ និងតស៊ូជំនះគ្រប់បែបយ៉ាងដើម្បីដោះស្រាយករណីទំនាស់ដីធ្លីរបស់ខ្លួន។ អ្វីដែលគួរឱ្យកត់សំគាល់នោះ គឺការចេះសហការណ៍គ្នាបានល្អដោយការចងក្រងជាសហគមន៍ និងរួបរួមកំលាំងគ្នានៅក្នុងការដោះស្រាយបញ្ហារួម។ ជាងនេះទៅទៀត គឺត្រូវចេះប្រមូល និងចងក្រងទុកនូវរាល់ឯកសារទាំងឡាយណាដែលមានសារៈប្រយោជន៍សំរាប់សហគមន៍ ដែលអាចទុកជាភស្តុតាងសំរាប់ធ្វើការបញ្ជាក់អះអាងនៅពេលចាំបាច់។ ដូច្នេះការចេះរួបរួមសាមគ្គីគ្នា គឺជាមធ្យោបាយមួយដ៏ប្រសើរដែលអាច ដោះស្រាយនូវបញ្ហាមួយចំនួនប្រកបដោយជោគជ័យ។ ម្យ៉ាងទៀត សហគមន៍ត្រូវចេះចូលរួមការពារធនធានធម្មជាតិ បរិស្ថាន និងទ្រព្យសម្បត្តិ រួមឱ្យបានគង់វង្ស និងធានាក្នុងការប្រើប្រាស់ធនធានទាំងនោះអោយមាននិរន្តរភាពដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងសហគមន៍។

*អត្ថបទដោយៈ សហគមន៍កំពង់សាមគ្គី ខេត្តកំពត*